ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៣ សរ

## សារាចរ

## ស្ដីពីការស្នើសុំលិខិតឆ្លងដែនផ្លូវការ និងការ ប្រើប្រាស់លិខិតឆ្លងដែនផ្លូវការសំរាប់មន្ត្រីកម្ពុជា

កន្លងមកថ្មីៗនេះមានមន្ត្រីកម្ពុជាមួយចំនួនតូចនៅក្នុងក្រសួង ស្ថាប័នខ្លះបានស្នើសុំលិខិតឆ្លងដែនផ្លូវការ និងប្រើប្រាស់លិខិតឆ្លងដែនផ្លូវការកម្ពុជាដោយមិនត្រឹមត្រូវដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរាជរដ្ឋាភិបាល និងព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីជៀសវាងកុំឱ្យមានបញ្ហាបែបនេះកើតមានជាបន្តបន្ទាប់ទៅថ្ងៃមុខ និងធានាឱ្យបាននូវការប្រើប្រាស់លិខិតឆ្លងដែនផ្លូវការកម្ពុជាឱ្យបានត្រឹមត្រូវ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ននានាឱ្យពិនិត្យបេសកកម្មឱ្យបានហ្មត់ចត់បំផុតមុននឹងស្នើសុំលិខិតឆ្លងដែនផ្លូវការពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ក្រោយពីបញ្ចប់បេសកកម្មនៅក្រៅប្រទេស មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័នទាំងអស់ត្រូវរក្សាទុកលិខិតឆ្លងដែនផ្លូវការដោយខ្លួនឯង ហើយត្រូវប្រើប្រាស់លិខិតឆ្លងដែនផ្លូវការនេះឱ្យបានត្រឹមត្រូវ ជៀសវាងការប្រើប្រាស់ខុសគោលដៅដែលនាំឱ្យប៉ះពាល់ដល់កិត្តិយសរាជរដ្ឋាភិបាលនិងព្រះរាជាណាចក្រកម្ពុជា ។

ទទួលបានសារាចរនេះហើយ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ